
យើងបានសមីការ (*) ទៅជា $\dfrac{\cos 2x \sin x}{-\sin x} = \cos\left(2x - \dfrac{\pi}{4}\right)$

$$\Leftrightarrow -\cos 2x = \cos\left(2x - \frac{\pi}{4}\right)$$

$$\Leftrightarrow \cos(2x - \pi) = \cos\left(2x - \frac{\pi}{4}\right)$$

$$\Leftrightarrow \begin{cases} 2x - \pi = 2x - \dfrac{\pi}{4} + 2k\pi \\ 2x - \pi = -2x + \dfrac{\pi}{4} + 2k\pi \end{cases}, k \in \mathbb{Z}$$

$$\Leftrightarrow \begin{cases} 0x = \dfrac{3\pi}{4} + 2k\pi \\ 4x = \dfrac{5\pi}{4} + 2k\pi \end{cases}, k \in \mathbb{Z}$$

$$\Leftrightarrow x = \frac{5\pi}{16} + \frac{k\pi}{2}, k \in \mathbb{Z}$$

ដោយ $x\in(\pi,2\pi)$ យើងបាន $x\in\left\{\frac{21\pi}{16},\frac{29\pi}{16}\right\}$

ដូចនេះ សមីការមានចម្លើយ $\boxed{x\in\left\{\frac{\pi}{16},\frac{9\pi}{16},\frac{21\pi}{16},\frac{29\pi}{16}\right\}}$

លំហាត់ទី៧ : ដោះស្រាយសមីការត្រីកោណមាត្រខាងក្រោម ៖

ក. $\sin x+\cos x+1+\sin 2x+\cos 2x=0$

ខ. $\cot x+\sin x(1+\tan x\tan\frac{x}{2})=4$

គ. $\frac{1}{\sin x}+\frac{1}{\sin(x-\frac{3\pi}{2})}=4\sin\left(\frac{7\pi}{4}-x\right)$

## ចំណោះស្រាយ

ក. $\sin x+\cos x+1+\sin 2x+\cos 2x=0$

$\Leftrightarrow \sin x+\cos x+1+2\sin x\cos x+2\cos^2 x-1=0$

$\Leftrightarrow (\sin x+\cos x)+2\cos x(\sin x+\cos x)=0$

$\Leftrightarrow (\sin x+\cos x)(1+2\cos x)=0$

$\Leftrightarrow \left[\begin{array}{l}\sin x+\cos x=0\\1+2\cos x=0\end{array}\right.$

$\Leftrightarrow \left[\begin{array}{l}\tan x=-1=\tan\left(-\frac{\pi}{4}\right)\\\cos x=-\frac{1}{2}=\cos\left(\frac{2\pi}{3}\right)\end{array}\right.$

$$\Leftrightarrow \begin{bmatrix} x=-\frac{\pi}{4}+k\pi \\ x=\pm\frac{2\pi}{3}+2k\pi \end{bmatrix}, k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=-\frac{\pi}{4}+k\pi\ ,\ x=\pm\frac{2\pi}{3}+2k\pi\ ,\ k\in\mathbb{Z}}$

ខ. $\cot x+\sin x(1+\tan x\tan\frac{x}{2})=4$

សមីការមានឫសកាលណា $\begin{cases}\cos x\neq 0\\ \cos\frac{x}{2}\neq 0\\ \sin x\neq 0\end{cases}$

$$\Leftrightarrow \begin{cases} x\neq\frac{\pi}{2}+k\pi=\frac{(2k+1)\pi}{2} \\ x\neq\pi+2k\pi=(2k+1)\pi \\ x\neq k\pi \end{cases}$$

$$\Leftrightarrow x\neq\frac{k\pi}{2}\ ,\ k\in\mathbb{Z}$$

ដោយ $1+\tan x\tan\frac{x}{2}=1+\frac{\sin x\cdot\sin\frac{x}{2}}{\cos x\cdot\cos\frac{x}{2}}$

$$=\frac{\cos x\cos\frac{x}{2}+\sin x\sin\frac{x}{2}}{\cos x\cos\frac{x}{2}}$$

$$= \frac{\cos\left(x-\frac{x}{2}\right)}{\cos x \cos\frac{x}{2}} = \frac{1}{\cos x}$$

យើងបាន សមីការអាចសរសេរ $\cot x + \sin x \cdot \frac{1}{\cos x} = 4$

$$\Leftrightarrow \frac{\cos^2 x + \sin^2 x}{\sin x \cos x} = 4$$

$$\Leftrightarrow \frac{2}{\sin 2x} = 4$$

$$\Leftrightarrow \sin 2x = \frac{1}{2} = \sin\frac{\pi}{6}$$

$$\Leftrightarrow \begin{cases} 2x = \frac{\pi}{6} + 2k\pi \\ 2x = \pi - \frac{\pi}{6} + 2k\pi \end{cases}, k \in \mathbb{Z}$$

$$\Rightarrow \begin{cases} x = \frac{\pi}{12} + k\pi \\ x = \frac{5\pi}{12} + k\pi \end{cases}, k \in \mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x = \frac{\pi}{12} + k\pi \text{ , } x = \frac{5\pi}{12} + k\pi \text{ , } k \in \mathbb{Z}}$

គ. $\frac{1}{\sin x} + \frac{1}{\sin(x-\frac{3\pi}{2})} = 4\sin\left(\frac{7\pi}{4} - x\right)$

ដោយ $\sin\left(x-\frac{3\pi}{2}\right) = \cos x$

សមីការមានឫសកាលណា $\begin{cases}\sin x \neq 0\\ \cos x \neq 0\end{cases}$

$$\Leftrightarrow \sin 2x \neq 0$$

$$\Leftrightarrow x \neq \frac{k\pi}{2}, k \in \mathbb{Z}$$

យើងបានសមីការទៅជា $\frac{1}{\sin x}+\frac{1}{\cos x}=4\sin\left(\frac{7\pi}{4}-x\right)$

$$\Leftrightarrow \frac{1}{\sin x}+\frac{1}{\cos x}=4\left(\sin\frac{7\pi}{4}\cos x-\sin x\cos\frac{7\pi}{4}\right)$$

$$\Leftrightarrow \frac{\cos x+\sin x}{\sin x\cos x}=4\left(-\frac{\sqrt{2}}{2}\cos x-\frac{\sqrt{2}}{2}\sin x\right)$$

$$\Leftrightarrow \frac{2(\sin x+\cos x)}{\sin 2x}=-2\sqrt{2}(\cos x+\sin x)$$

$$\Leftrightarrow 2(\sin x+\cos x)\left(\frac{1}{\sin 2x}+\sqrt{2}\right)=0$$

$$\Leftrightarrow \left[\begin{array}{l}\sin x+\cos x=0\\ \dfrac{1}{\sin 2x}+\sqrt{2}=0\end{array}\right.$$

$$\Leftrightarrow \left[\begin{array}{l}\tan x=-1=\tan\left(-\dfrac{\pi}{4}\right)\\ \sin 2x=-\dfrac{\sqrt{2}}{2}=\sin\left(-\dfrac{\pi}{4}\right)\end{array}\right.$$

$$\Leftrightarrow \begin{cases} x=-\dfrac{\pi}{4}+k\pi \\ 2x=-\dfrac{\pi}{4}+2k\pi \quad k\in\mathbb{Z} \\ 2x=\pi+\dfrac{\pi}{4}+2k\pi \end{cases}$$

$$\Leftrightarrow \begin{cases} x=-\dfrac{\pi}{4}+k\pi \\ x=-\dfrac{\pi}{8}+k\pi \ , k\in\mathbb{Z} \\ x=\dfrac{5\pi}{8}+k\pi \end{cases}$$

ដូចនេះ សមីការមានចម្លើយ :

$$x=-\frac{\pi}{4}+k\pi\ ,\ x=-\frac{\pi}{8}+k\pi\ ,\ x=\frac{5\pi}{8}+k\pi\ ,\ k\in\mathbb{Z}$$

**លំហាត់ទី៨:ដោះស្រាយសមីការ** $\cos\left[\dfrac{\pi}{4}\left(3x-\sqrt{9x^2-16x-80}\right)\right]=1$

## ចំណោះស្រាយ

សមីការមានឫសកាលណា $9x^2-16x-80\geq 0$

នោះ $x\in(-\infty\ ,-\dfrac{20}{9}]\cup[4\ ,+\infty)$

យើងបាន $\cos\left[\dfrac{\pi}{4}\left(3x-\sqrt{9x^2-16x-80}\right)\right]=1$

$$\Leftrightarrow \frac{\pi}{4}\left(3x-\sqrt{9x^2-16x-80}\right)=2k\pi\ ,\ k\in\mathbb{Z}$$

$\Leftrightarrow 3x-\sqrt{9x^2-16x-80}=8k$

$\Leftrightarrow 3x-8k=\sqrt{9x^2-16x-80}$ (#)

នោះ សមីការមានឫសកាលណា $3x-8k\geq 0\Rightarrow x\geq \frac{8k}{3}$

លើកសមីការ (#) ជាការេគេបាន ៖

$\Leftrightarrow (3x-8k)^2=\left(\sqrt{9x^2-16x-80}\right)^2$

$\Leftrightarrow 9x^2-48kx+64k^2=9x^2-16x-80$

$\Leftrightarrow (16-48k)x=-64k^2-80$

$\Rightarrow x=\frac{-64k^2-80}{16-48k}=\frac{4k^2+5}{3k-1}$

ដូចនេះ សមីការមានឫស $\boxed{x=\frac{4k^2+5}{3k-1},\ k\in\mathbb{Z}}$

លំហាត់ទី៩: ដោះស្រាយសមីការត្រីកោណមាត្រខាងក្រោម ៖

ក. $2\sin^2 x+3\sin x-5=0$

ខ. $2\cos^2 2x+3\cos 2x+1=0$

គ. $\tan^4 x-2\tan^2 x+1=0$

ឃ. $\cot^2 x+2\cot x-3=0$

## ដំណោះស្រាយ

ក. $2\sin^2 x+3\sin x-5=0$

តាង $t=\sin x$ ដែល $-1\leq t\leq 1$

យើងបានសមីការទៅជា $2t^2+3t-5=0$

$$\Delta = 9+40 = 49 = 7^2$$

$$t_1 = \frac{-3+7}{2\cdot 2} = 1$$

$$t_2 = \frac{-3-7}{2\cdot 22} = -\frac{5}{2} < -1 \text{ (មិនយក)}$$

តែ $t=\sin x$ យើងបាន $\sin x = 1 \Rightarrow x = \frac{\pi}{2}+2k\pi \ , k\in\mathbb{Z}$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{\pi}{2}+2k\pi \ , k\in\mathbb{Z}}$

ខ. $2\cos^2 2x+3\cos 2x+1=0$

តាង $t=\cos 2x$ ដែល $-1\le t\le 1$

យើងបានសមីការទៅជា $2t^2+3t+1=0$

ដោយ $a-b+c=2-3+1=0$

នោះ $t_1=-1, t_2=-\frac{c}{a}=-\frac{1}{2}$

តែ $t=\cos 2x$ យើងបាន:

- $t=1 \Leftrightarrow \cos 2x=-1$

$$\Leftrightarrow 2x=\pi+2k\pi \ , k\in\mathbb{Z}$$

$$\Rightarrow x=\frac{\pi}{2}+k\pi \ , k\in\mathbb{Z}$$

$$t=-\frac{1}{2} \Leftrightarrow \cos 2x=-\frac{1}{2}=\cos\left(\frac{2\pi}{3}\right)$$

$$\Leftrightarrow 2x=\pm\frac{2\pi}{3}+2k\pi$$

$$\Rightarrow x=\pm\frac{\pi}{3}+k\pi\ ,k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{\pi}{2}+k\pi\ ,x=\pm\frac{\pi}{3}+k\pi\ ,k\in\mathbb{Z}}$

គ. $\tan^4 x-2\tan^2 x+1=0$

សមីការមានចម្លើយកាលណា $\cos x\neq 0\Rightarrow x\neq\frac{\pi}{2}+k\pi\ ,k\in\mathbb{Z}$

តាង $t=\tan x\ ,t\in\mathbb{R}$

យើងបានសមីការទៅជា $t^4-2t^2+1=0$

$$\Leftrightarrow (t^2-1)^2=0$$
$$\Leftrightarrow t^2-1=0$$
$$\Rightarrow t=\pm 1$$

- $t=1\Leftrightarrow\tan x=1=\tan\frac{\pi}{4}$

$$\Rightarrow x=\frac{\pi}{4}+k\pi\ ,k\in\mathbb{Z}$$

- $t=-1\Leftrightarrow\tan x=-1=\tan\left(-\frac{\pi}{4}\right)$

$$\Rightarrow x=-\frac{\pi}{4}+k\pi\ ,k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\pm\frac{\pi}{4}+k\pi\ ,k\in\mathbb{Z}}$

ឃ. $\cot^2 x+2\cot x-3=0$

សមីការមានន័យកាលណា $\sin x\neq 0\Rightarrow x\neq k\pi\ ,k\in\mathbb{Z}$

តាង $t=\cot x\ ,t\in\mathbb{R}$

យើងបានសមីការទៅជា $t^2+2t-3=0$

ដោយ $a+b+c=1+2-3=0$

នោះ $t_1=1, t_2=\frac{c}{a}=-\frac{3}{1}=-3$

- $t=1\Leftrightarrow \cot x=1=\cot\frac{\pi}{4}$

$$\Rightarrow x=\frac{\pi}{4}+k\pi \ , k\in\mathbb{Z}$$

- $t=-3\Leftrightarrow \cot x=-3$

$$\Rightarrow x=\operatorname{arc}\cot(-3)+k\pi, k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ

$$x=\frac{\pi}{4}+k\pi \ , \ x=\operatorname{arc}\cot(-3)=k\pi, k\in\mathbb{Z}$$

លំហាត់ទី១០ : ដោះស្រាយសមីការត្រីកោណមាត្រខាងក្រោម៖

ក. $\sin^4 x+\cos^4 x=\sin 2x-\frac{1}{2}$

ខ. $\sin^4 x+\cos^4 x=-\frac{1}{2}\sin 2x$

គ. $\frac{\sin^4 x+\cos^4 x}{\cos^2 x-\sin^2 x}=-\frac{1}{2}\tan 2x$

ឃ. $\sin^4 x+\cos^4 x=\frac{11}{8}-\sin 2x$

## ចំណោះស្រាយ

ក. $\sin^4 x+\cos^4 x=\sin 2x-\frac{1}{2}$

$\Leftrightarrow (\cos^2 x+\sin^2 x)^2-2\sin^2 x\cos^2 x=\sin 2x-\frac{1}{2}$

$\Leftrightarrow 1^2-\frac{1}{2}\sin^2 2x-\sin 2x+\frac{1}{2}=0$

$\Leftrightarrow \sin^2 2x+2\sin 2x-3=0$

តាង $t=\sin 2x$ ដែល $-1\le t\le 1$

នោះសមីការទៅជា $t^2+2t-3=0$

ដោយ $a+b+c=1+2-3=0$

នោះ $t_1=1$ , $t_2=\frac{c}{a}=-3<-1$ (មិនយក)

- $\sin 2x=1$

$\Leftrightarrow 2x=\frac{\pi}{2}+2k\pi$ , $k\in\mathbb{Z}$

$\Rightarrow x=\frac{\pi}{4}+k\pi$ , $k\in\mathbb{Z}$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{\pi}{4}+k\pi \ , k\in\mathbb{Z}}$

ខ. $\sin^4 x+\cos^4 x=-\frac{1}{2}\sin 2x$

$\Leftrightarrow (\sin^2 x+\cos^2 x)^2-2\sin^2 x\cos^2 x=-\frac{1}{2}\sin 2x$

$\Leftrightarrow 1^2-\frac{1}{2}\sin^2 2x+\frac{1}{2}\sin 2x=0$

$\Leftrightarrow \sin^2 2x-\sin 2x-2=0$

តាង $\sin 2x = t$ ដែល $-1 \le t \le 1$

យើងបានសមីការទៅជា $t^2 - t - 2 = 0$

ដោយ $b = a + c$ គឺ $-1 = 1 - 2$

នោះ $t_1 = -1$ , $t_2 = -\frac{c}{a} = 2 \notin [-1,1]$ (មិនយក)

តែ $t = \sin 2x$ យើងបាន $\sin 2x = -1$

$$\Leftrightarrow 2x = -\frac{\pi}{2} + 2k\pi \ , \ k \in \mathbb{Z}$$

$$\Rightarrow x = -\frac{\pi}{4} + k\pi \ , k \in \mathbb{Z}$$

ដូចនេះ សមីការមានឫស $\boxed{x = -\frac{\pi}{4} + k\pi \ , k \in \mathbb{Z}}$

គ. $\frac{\sin^4 x + \cos^4 x}{\cos^2 x - \sin^2 x} = -\frac{1}{2}\tan 2x$

$\Leftrightarrow \frac{\sin^4 x + \cos^4 x}{\cos 2x} = -\frac{\sin 2x}{2\cos 2x}$

សមីការមានន័យកាលណា $\cos 2x \neq 0$

$$\Leftrightarrow 2x \neq \frac{\pi}{2} + k\pi \ , k \in \mathbb{Z}$$

$$\Rightarrow x \neq \frac{\pi}{4} + \frac{k\pi}{2} \ , k \in \mathbb{Z}$$

ដោយ $\sin^4 x + \cos^4 x = (\sin^2 x + \cos^2 x)^2 - 2\sin^2 x \cos^2 x$

$$= 1 - \frac{1}{2}\sin^2 2x$$

នោះសមីការទៅ $\frac{1 - \frac{1}{2}\sin^2 2x}{\cos 2x} = -\frac{\sin 2x}{2\cos 2x}$

$$\Leftrightarrow 1-\frac{1}{2}\sin^2 2x=-\frac{1}{2}\sin 2x$$

$$\Leftrightarrow \sin^2 2x-\sin 2x-2=0$$

តាង $\sin 2x=t$ ដែល $-1\le t\le 1$

យើងបានសមីការទៅជា $t^2-t-2=0$

ដោយ $b=a+c$ គឺ $-1=1-2$

នោះ $t_1=-1$ , $t_2=-\frac{c}{a}=2\notin[-1,1]$ (មិនយក)

តែ $t=\sin 2x$ យើងបាន $\sin 2x=-1$

$$\Leftrightarrow 2x=-\frac{\pi}{2}+2k\pi \ , \ k\in\mathbb{Z}$$

$$\Rightarrow x=-\frac{\pi}{4}+k\pi \ , k\in\mathbb{Z}$$

ដូចនេះ សមីការមានឫស $\boxed{x=-\frac{\pi}{4}+k\pi \ , k\in\mathbb{Z}}$

ឃ. $\sin^4 x+\cos^4 x=\frac{11}{8}-\sin 2x$

$$\Leftrightarrow (\sin^2 x+\cos^2 x)^2-2\sin^2 x\cos^2 x=\frac{11}{8}-\sin 2x$$

$$\Leftrightarrow 1-\frac{1}{2}\sin^2 2x=\frac{11}{8}-\sin 2x$$

$$\Leftrightarrow 4\sin^2 2x-8\sin 2x+3=0$$

តាង $t=\sin 2x$ ដែល $-1\le t\le 1$

យើងបានសមីការទៅជា $4t^2-8t+3=0$

$$\Delta'=16-12=4=2^2$$

$$t_1=\frac{4-2}{4}=\frac{1}{2}$$

$$t_2=\frac{4+2}{4}=\frac{3}{2}>1 \quad (\text{មិនយក})$$

តែ $t=\sin 2x$ យើងបាន $\sin 2x=\frac{1}{2}=\sin\frac{\pi}{6}$

$$\Leftrightarrow\begin{cases}2x=\frac{\pi}{6}+2k\pi\\ 2x=\pi-\frac{\pi}{6}+2k\pi\end{cases},\ k\in\mathbb{Z}$$

$$\Rightarrow\begin{cases}x=\frac{\pi}{12}+k\pi\\ x=\frac{5\pi}{12}+k\pi\end{cases},\ k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{\pi}{12}+k\pi\ ,\ x=\frac{5\pi}{12}+k\pi\ ,\ k\in\mathbb{Z}}$

លំហាត់ទី១១ : ដោះស្រាយសមីការត្រីកោណមាត្រខាងក្រោម៖

ក. $\cos^2\left(x+\frac{\pi}{3}\right)+2\sin\left(-x+\frac{\pi}{6}\right)=3$

ខ. $\sin^4 2x+\cos^4 2x=\sin 2x\cos 2x$

គ. $\sin^8 x+\cos^8 x=\frac{17}{16}\cos^2 2x$

ឃ. $\sin^6 x+\cos^6 x-\sin 2x=0$

ង. $\cos^4\frac{x}{5}+\sin^2\frac{x}{5}=1$

## ចំណោះស្រាយ

ក. $\cos^2\left(x+\frac{\pi}{3}\right)+2\sin\left(-x+\frac{\pi}{6}\right)=3$

ដោយ $\sin\left(-x+\frac{\pi}{6}\right)=\cos\left[\frac{\pi}{2}-\left(-x+\frac{\pi}{6}\right)\right]=\cos\left(x+\frac{\pi}{3}\right)$

តាង $t=\cos\left(x+\frac{\pi}{3}\right)$ ដែល $-1\le t\le 1$

យើងបានសមីការទៅជា $t^2+2t=3\Leftrightarrow t^2+2t-3=0$

ដោយ $a+b+c=1+2-3=0$

នោះ $t_1=1$ , $t_2=\frac{c}{a}=-\frac{3}{1}=-3<-1$ (មិនយក)

តែ $t=\cos\left(x+\frac{\pi}{3}\right)$ យើងបាន $\cos\left(x+\frac{\pi}{3}\right)=1$

$$x+\frac{\pi}{3}=2k\pi \ , \ k\in\mathbb{Z}$$

$$\Rightarrow x=-\frac{\pi}{3}+2k\pi \ , \ k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=-\frac{\pi}{3}+2k\pi \ , \ k\in\mathbb{Z}}$

ខ. $\sin^4 2x+\cos^4 2x=\sin 2x\cos 2x$

$$\Leftrightarrow (\sin^2 2x+\cos^2 2x)^2-2\sin^2 2x\cos^2 2x=\frac{1}{2}\sin 4x$$

$$\Leftrightarrow 1-\frac{1}{2}\sin^2 4x=\frac{1}{2}\sin 4x$$

$$\Leftrightarrow \sin^2 4x+\sin 4x-2=0$$

តាង $t=\sin 4x$ ដែល $-1\le t\le 1$

យើងបានសមីការទៅជា $t^2+t-2=0$

ដោយ $a+b+c=1+1-2=0$

នោះ $t_1=1$ , $t_2=\dfrac{c}{a}=-2<-1$ (មិនយក)

តែ $t=\sin 4x$ យើងបាន $\sin 4x=1$

$$\Leftrightarrow 4x=\frac{\pi}{2}+2k\pi \ , \ k\in\mathbb{Z}$$

$$\Rightarrow x=\frac{\pi}{8}+\frac{k\pi}{2} \ , \ k\in\mathbb{Z}$$

ដូចនេះ សមីការមានឫស $\boxed{x=\dfrac{\pi}{8}+\dfrac{k\pi}{2} \ , \ k\in\mathbb{Z}}$

គ. $\sin^8 x+\cos^8 x=\dfrac{17}{16}\cos^2 2x$

យើងមាន $\sin^8 x+\cos^8 x=(\sin^4 x+\cos^4 x)^2-2\sin^4 x\cos^4 x$

$$=\left[(\sin^2 x+\cos^2 x)^2-2\sin^2 x\cos^2 x\right]^2-2\left(\frac{1}{2}\sin 2x\right)^4$$

$$=\left(1-\frac{1}{2}\sin^2 2x\right)^2-\frac{1}{8}\sin^4 2x$$

យើងបាន $\left(1-\dfrac{1}{2}\sin^2 2x\right)^2-\dfrac{1}{8}\sin^4 2x=\dfrac{17}{16}\cos^2 2x$

$$\Leftrightarrow\left(1-\frac{1}{2}\sin^2 2x\right)^2-\frac{1}{8}\sin^4 2x=\frac{17}{16}\left(1-\sin^2 2x\right)$$

តាង $t=\sin^2 2x$ ដែល $0\le t\le 1$

យើងបាន $\left(1-\dfrac{t}{2}\right)^2-\dfrac{1}{8}t^2=\dfrac{17}{16}(1-t)$

$$\Leftrightarrow 1-t+\frac{t^2}{4}-\frac{t^2}{8}=\frac{17}{16}-\frac{17}{16}t$$

$$\Leftrightarrow 2t^2+t-1=0$$

ដោយ $a-b+c=2-1+(-1)=0$

នោះ $t_1=-1<0$ (មិនយក)

$$t_2=-\frac{c}{a}=\frac{1}{2}$$

តែ $t=\sin^2 2x$ យើងបាន $\sin^2 2x=\frac{1}{2}$

$$\Leftrightarrow \frac{1-\cos 4x}{2}=\frac{1}{2}$$

$$\Leftrightarrow \cos 4x=0$$

$$\Leftrightarrow 4x=\frac{\pi}{2}+k\pi \ , \ k\in\mathbb{Z}$$

$$\Rightarrow x=\frac{\pi}{8}+\frac{k\pi}{4} \ , k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{\pi}{8}+\frac{k\pi}{4} \ , k\in\mathbb{Z}}$

ឃ. $\sin^6 x+\cos^6 x-\sin 2x=0$

$$\Leftrightarrow (\sin^2 x+\cos^2 x)^3-3\sin^2 x\cos^2 x(\sin^2 x+\cos^2 x)-\sin 2x=0$$

$$\Leftrightarrow 1-\frac{3}{4}\sin^2 2x-\sin 2x=0$$

$$\Leftrightarrow 3\sin^2 2x+4\sin 2x+4=0$$

តាង $t=\sin 2x$ ដែល $-1\le t\le 1$

យើងបានសមីការទៅជា $3t^2+4t-4=0$

$$\Delta' = 4+12 = 16$$

$$t_1 = \frac{-2+4}{3} = \frac{2}{3}$$

$$t_2 = \frac{-2-4}{3} = -2 < -1 (\text{មិនយក})$$

តែ $t = \sin 2x$ យើងបាន $\sin 2x = \frac{2}{3}$

$$\Leftrightarrow \begin{cases} 2x = \arcsin\left(\frac{2}{3}\right) + 2k\pi \\ 2x = \pi - \arcsin\left(\frac{2}{3}\right) + 2k\pi \end{cases}, k \in \mathbb{Z}$$

$$\Rightarrow \begin{cases} x = \frac{1}{2}\arcsin\left(\frac{2}{3}\right) + k\pi \\ x = \frac{\pi}{2} - \frac{1}{2}\arcsin\left(\frac{2}{3}\right) + k\pi \end{cases}, \ k \in \mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ

$$\boxed{x = \frac{1}{2}\arcsin\left(\frac{2}{3}\right) + k\pi \ , \ x = \frac{\pi}{2} - \frac{1}{2}\arcsin\left(\frac{2}{3}\right) + k\pi , k \in \mathbb{Z}}$$

ង. $\cos^4 \frac{x}{5} + \sin^2 \frac{x}{5} = 1$

$$\Leftrightarrow \cos^4 \frac{x}{5} + 1 - \cos^2 \frac{x}{5} = 1$$

$$\Leftrightarrow \cos^4 \frac{x}{5} - \cos^2 \frac{x}{5} = 0$$

$$\Leftrightarrow \cos^2 \frac{x}{5}\left(\cos^2 \frac{x}{5} - 1\right) = 0$$

$$\Leftrightarrow \begin{cases} \cos^2\dfrac{x}{5}=0 \\ \cos^2\dfrac{x}{5}-1=0 \end{cases}$$

$$\Leftrightarrow \begin{cases} \cos\dfrac{x}{5}=0 \\ \cos\dfrac{x}{5}=\pm 1 \end{cases}$$

$$\Leftrightarrow \begin{cases} \dfrac{x}{5}=\dfrac{\pi}{2}+k\pi \\ \dfrac{x}{5}=k\pi \end{cases}, \ k\in\mathbb{Z}$$

$$\Rightarrow \begin{cases} x=\dfrac{5\pi}{2}+5k\pi \\ x=5k\pi \end{cases}, \ k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\dfrac{5\pi}{2}+5k\pi\ ,\ x=5k\pi\ ,\ k\in\mathbb{Z}}$

**លំហាត់ទី១២៖ ដោះស្រាយសមីការត្រីកោណមាត្រខាងក្រោម៖**

ក. $\dfrac{\cos x(2\sin x+3\sqrt{2})-2\cos^2 x-1}{1+\sin 2x}=1$

ខ. $\cos\left(2x+\dfrac{\pi}{4}\right)+\cos\left(2x-\dfrac{\pi}{4}\right)+4\sin x=2+\sqrt{2}\left(1-\sin x\right)$

គ. $3\cot^2 x+2\sqrt{2}\sin^2 x=(2+3\sqrt{2})\cos x$

ឃ. $\dfrac{4\sin^2 2x+6\sin^2 x-9-3\cos 2x}{\cos x}=0$

ង. $\sin 2x(\cot x+\tan 2x)=4\cos^2 x$

## ចំណោះស្រាយ

ក. $\dfrac{\cos x(2\sin x+3\sqrt{2})-2\cos^2 x-1}{1+\sin 2x}=1$

សមីការមានឫសកាលណា $1+\sin 2x\neq 0$

$$\Leftrightarrow \sin 2x\neq -1$$

$$\Leftrightarrow 2x\neq -\frac{\pi}{2}+2k\pi \ , \ k\in\mathbb{Z}$$

$$\Rightarrow x\neq -\frac{\pi}{4}+k\pi \ , k\in\mathbb{Z}$$

យើងបានសមីការទៅជា

$$\cos x(2\sin x+3\sqrt{2})-2\cos^2 x-1=1+\sin 2x$$

$$\Leftrightarrow \sin 2x+3\sqrt{2}\cos x-2\cos^2 x-1=1+\sin 2x$$

$$\Leftrightarrow 2\cos^2 x-3\sqrt{2}\cos x+2=0$$

តាង $t=\cos x$ ដែល $-1\le t\le 1$

យើងបាន $2t^2-3\sqrt{2}t+2=0$

$$\Delta=18-16=2$$

$$t_1=\frac{3\sqrt{2}-\sqrt{2}}{2\cdot 2}=\frac{\sqrt{2}}{2}$$

$$t_2=\frac{3\sqrt{2}+\sqrt{2}}{2\cdot 2}=\sqrt{2}>1 \text{ (មិនយក)}$$

តែ $t=\cos x$ យើងបាន $\cos x=\dfrac{\sqrt{2}}{2}=\cos\dfrac{\pi}{4}$

$$\Rightarrow x=\pm\frac{\pi}{4}+2k\pi \ , \ k\in\mathbb{Z}$$

តែ $x\neq -\dfrac{\pi}{4}+k\pi \ , k\in\mathbb{Z} \Rightarrow x\neq -\dfrac{\pi}{4}+2k\pi , k\in\mathbb{Z}$

ដូចនេះ សមីការមានមានចម្លើយ $\boxed{x=\frac{\pi}{4}+2k\pi\ ,\ k\in\mathbb{Z}}$

ខ. $\cos\left(2x+\frac{\pi}{4}\right)+\cos\left(2x-\frac{\pi}{4}\right)+4\sin x=2+\sqrt{2}\left(1-\sin x\right)$

ដោយ $\cos\left(2x+\frac{\pi}{4}\right)+\cos\left(2x-\frac{\pi}{4}\right)=2\cos\frac{2x+\frac{\pi}{4}+2x-\frac{\pi}{4}}{2}\cos\frac{2x+\frac{\pi}{4}-2x+\frac{\pi}{4}}{2}$

$$=2\cos 2x\cos\frac{\pi}{4}$$

$$=\sqrt{2}\cos 2x$$

យើងបានសមីការទៅជា $\sqrt{2}\cos 2x+4\sin x=2+\sqrt{2}\left(1-\sin x\right)$

$$\Leftrightarrow \sqrt{2}\left(1-2\sin^2 x\right)+4\sin x=2+\sqrt{2}-\sqrt{2}\sin x$$

$$\Leftrightarrow \sqrt{2}-2\sqrt{2}\sin^2 x+4\sin x-2-\sqrt{2}+\sqrt{2}\sin x=0$$

$$\Leftrightarrow 2\sqrt{2}\sin^2 x-(4+\sqrt{2})\sin x+2=0$$

$$\Leftrightarrow 2\sin^2 x-(2\sqrt{2}+1)\sin x+\sqrt{2}=0$$

$$\Delta=\left[-(2\sqrt{2}+1)\right]^2-4\cdot 2\cdot\sqrt{2}$$

$$=8+4\sqrt{2}+1-8\sqrt{2}$$

$$=9-4\sqrt{2}$$

$$=(2\sqrt{2}-1)^2$$

$$\sin x_1=\frac{(2\sqrt{2}+1)-(2\sqrt{2}-1)}{4}=\frac{1}{2}$$

$$\sin x_2=\frac{(2\sqrt{2}+1+(2\sqrt{2}-1)}{4}=\sqrt{2}>1\ (\text{មិនយក})$$

យើងបាន $\sin x=\frac{1}{2}$

$$\Rightarrow \begin{cases} x=\dfrac{\pi}{6}+2k\pi \\ x=\dfrac{5\pi}{6}+2k\pi \end{cases}, k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\dfrac{\pi}{6}+2k\pi\ ,\ x=\dfrac{5\pi}{6}+2k\pi\ ,\ k\in\mathbb{Z}}$

គ. $3\cot^2 x+2\sqrt{2}\sin^2 x=(2+3\sqrt{2})\cos x$

សមីការមានឫសកាលណា $\sin x\neq 0\Rightarrow x\neq k\pi\ ,\ k\in\mathbb{Z}$

ដោយ $\sin^2 x=1-\cos^2 x$ និង $\cot^2 x=\dfrac{\cos^2 x}{\sin^2 x}$

យើងបាន សមីការទៅជា $3\dfrac{\cos^2 x}{\sin^2 x}+2\sqrt{2}\sin^2 x=(2+3\sqrt{2})\cos x$

$$\Leftrightarrow 3\frac{\cos^2 x}{\sin^4 x}+2\sqrt{2}=(2+3\sqrt{2})\frac{\cos x}{\sin^2 x}$$

$$\Leftrightarrow 3\left(\frac{\cos x}{\sin^2 x}\right)^2-(2+3\sqrt{2})\left(\frac{\cos x}{\sin^2 x}\right)+2\sqrt{2}=0$$

តាង $t=\dfrac{\cos x}{\sin^2 x}$ យើងបាន $3t^2-(2+3\sqrt{2})t+2\sqrt{2}=0$

$$\begin{aligned}\Delta&=\left[-(2+3\sqrt{2})\right]^2-4\cdot 3\cdot 2\sqrt{2}\\&=4+12\sqrt{2}+18-24\sqrt{2}\\&=22-12\sqrt{2}\\&=(3\sqrt{2}-2)^2\end{aligned}$$

$$t_1=\frac{(2+3\sqrt{2})-(3\sqrt{2}-2)}{6}=\frac{2}{3}$$

$$t_2=\frac{(2+3\sqrt{2})+(3\sqrt{2}-2)}{6}=\sqrt{2}$$

តែ $t=\dfrac{\cos x}{\sin^2 x}$ យើងបាន ៖

- $t=\dfrac{2}{3}\Leftrightarrow \dfrac{\cos x}{\sin^2 x}=\dfrac{2}{3}$

$\Leftrightarrow 3\cos x=2(1-\cos^2 x)$

$\Leftrightarrow 2\cos^2 x+3\cos x-2=0$

$\Leftrightarrow (2\cos x-1)(\cos x+2)=0$

$\Leftrightarrow \left[\begin{array}{l}2\cos x-1=0\\ \cos x+2=0\end{array}\right.$

$\Leftrightarrow \left[\begin{array}{l}\cos x=\dfrac{1}{2}\\ \cos x=-2<-1(\text{មិនយក})\end{array}\right.$

$\Leftrightarrow \cos x=\cos\dfrac{\pi}{3}$

$\Rightarrow x=\pm\dfrac{\pi}{3}+2k\pi\ ,k\in\mathbb{Z}$

- $t=\sqrt{2}\Leftrightarrow \dfrac{\cos x}{\sin^2 x}=\sqrt{2}$

$\Leftrightarrow \cos x=\sqrt{2}(1-\cos^2 x)$

$\Leftrightarrow \sqrt{2}\cos^2 x+\cos x-\sqrt{2}=0$

$\Leftrightarrow \left(\sqrt{2}\cos x-1\right)\left(\cos x-\sqrt{2}\right)=0$

$\Leftrightarrow \left[\begin{array}{l}\cos x=\dfrac{\sqrt{2}}{2}\\ \cos x=\sqrt{2}>1\,(\text{មិនយក})\end{array}\right.$

$\Leftrightarrow \cos x=\cos\dfrac{\pi}{4}\ \Rightarrow x=\pm\dfrac{\pi}{4}+2k\pi\ ,k\in\mathbb{Z}$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\pm\frac{\pi}{3}+2k\pi, x=\pm\frac{\pi}{4}+2k\pi \ , k\in\mathbb{Z}}$

ឃ. $\frac{4\sin^2 2x+6\sin^2 x-9-3\cos 2x}{\cos x}=0$

សមីការមានឫសកាលណា $\cos x\neq 0\Rightarrow x\neq\frac{\pi}{2}+k\pi\ , k\in\mathbb{Z}$

ដោយ $\sin^2 2x=1-\cos^2 2x$ , $\sin^2 x=\frac{1-\cos 2x}{2}$

យើងបានសមីការទៅជា $4(1-\cos^2 2x)+6\cdot\frac{1-\cos 2x}{2}-9-3\cos 2x=0$

$\Leftrightarrow 4-4\cos^2 2x+3-3\cos 2x-9-3\cos 2x=0$

$\Leftrightarrow -4\cos^2 2x-6\cos 2x-2=0$

$\Leftrightarrow 2\cos^2 2x+3\cos 2x+1=0$

$\Leftrightarrow (\cos 2x+1)(\cos 2x+\frac{1}{2})=0$

$\Leftrightarrow \left[\begin{array}{l}\cos 2x=-1\\ \cos 2x=-\frac{1}{2}\end{array}\right.$

$\Leftrightarrow \left[\begin{array}{l}2x=\pi+2k\pi\\ 2x=\pm\frac{2\pi}{3}+2k\pi\end{array}\right. , k\in\mathbb{Z}$

$\Rightarrow \left[\begin{array}{l}x=\frac{\pi}{2}+k\pi\\ x=\pm\frac{\pi}{3}+k\pi\end{array}\right. , k\in\mathbb{Z}$

តែ $x\neq\frac{\pi}{2}+k\pi\ , k\in\mathbb{Z}$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\pm\frac{\pi}{3}+k\pi\ , k\in\mathbb{Z}}$

ង. $\sin 2x(\cot x+\tan 2x)=4\cos^2 x$

សមីការមានឫសកាលណា $\begin{cases}\sin x\neq 0\\ \cos 2x\neq 0\end{cases}\Rightarrow\begin{cases}x\neq k\pi\\ x\neq\dfrac{\pi}{4}+\dfrac{k\pi}{2}\end{cases},k\in\mathbb{Z}$

យើងបាន $\sin 2x(\cot x+\tan 2x)=4\cos^2 x$

$$\Leftrightarrow 2\sin x\cos x\left(\frac{\cos x}{\sin x}+\frac{\sin 2x}{\cos 2x}\right)=4\cos^2 x$$

$$\Leftrightarrow 2\cos^2 x+\frac{\sin^2 2x}{\cos 2x}=4\cos^2 x$$

$$\Leftrightarrow \frac{1-\cos^2 2x}{\cos 2x}=2\cos^2 x$$

$$\Leftrightarrow (1-\cos 2x)(1+\cos 2x)=2\cos 2x\left(\frac{1+\cos 2x}{2}\right)$$

$$\Leftrightarrow (1+\cos 2x)(1-2\cos 2x)=0$$

$$\Leftrightarrow\left[\begin{array}{l}\cos 2x=-1\\ \cos 2x=\dfrac{1}{2}\end{array}\right.$$

$$\Leftrightarrow\left[\begin{array}{l}2x=\pi+2k\pi\\ 2x=\pm\dfrac{\pi}{3}+2k\pi\end{array}\right.,k\in\mathbb{Z}$$

$$\Rightarrow\left[\begin{array}{l}x=\dfrac{\pi}{2}+k\pi\\ x=\pm\dfrac{\pi}{6}+k\pi\end{array}\right.,k\in\mathbb{Z}$$

តែ $x\neq\dfrac{\pi}{4}+\dfrac{k\pi}{2},k\in\mathbb{Z}$ នោះ $x=\dfrac{\pi}{2}+k\pi$ (មិនយក)

ដូចនេះ សមីការមានចម្លើយ $\boxed{x=\pm\dfrac{\pi}{6}+k\pi,k\in\mathbb{Z}}$

លំហាត់ទី១៣៖ ដោះស្រាយសមីការត្រីកោណមាត្រខាងក្រោម៖

ក. $\sin^4 x+\cos^4 x=\frac{7}{8}\cot\left(x+\frac{\pi}{3}\right)\cot\left(\frac{\pi}{6}-x\right)$

ខ. $5\sin x-2=3(1-\sin x)\tan^2 x$

គ. $\cos^2 3x\cos 2x-\cos^2 x=0$

ឃ. $\cos^4 x+\sin^4 x+\cos\left(x-\frac{\pi}{4}\right)\sin\left(3x-\frac{\pi}{4}\right)-\frac{3}{2}=0$

ង. $\frac{2(\sin^6 x+\cos^6 x)-\sin x\cos x}{\sqrt{2}-2\sin x}=0$

## ចំណោះស្រាយ

ក. $\sin^4 x+\cos^4 x=\frac{7}{8}\cot\left(x+\frac{\pi}{3}\right)\cot\left(\frac{\pi}{6}-x\right)$

សមីការមានឫសកាលណា $\begin{cases}\sin\left(x+\frac{\pi}{3}\right)\neq 0\\ \sin\left(\frac{\pi}{6}-x\right)\neq 0\end{cases}$

$$\Rightarrow\begin{cases}x\neq -\frac{\pi}{3}+k\pi\\ x\neq\frac{\pi}{6}+k\pi\end{cases},k\in\mathbb{Z}$$

ដោយ $\cot\left(\frac{\pi}{6}-x\right)=\tan\left[\frac{\pi}{2}-\left(\frac{\pi}{6}-x\right)\right]=\tan\left(\frac{\pi}{3}+x\right)$

នោះ $\cot\left(x+\frac{\pi}{3}\right)\cot\left(\frac{\pi}{6}-x\right)=\cot\left(\frac{\pi}{3}+x\right)\cdot\tan\left(\frac{\pi}{3}+x\right)=1$

ហើយ $\sin^4 x+\cos^4 x=\left(\sin^2 x+\cos^2 x\right)^2-2\sin^2 x\cos^2 x$

$$=1-\frac{1}{2}\sin^2 2x$$
$$=1-\frac{1}{2}\left(\frac{1-\cos 4x}{2}\right)$$
$$=\frac{4-\cos 4x}{4}$$

យើងបាន សមីការទៅជា $\frac{4-\cos 4x}{4}=\frac{7}{8}$

$$\Leftrightarrow 8-2\cos 4x=7$$
$$\Leftrightarrow \cos 4x=\frac{1}{2}=\cos\frac{\pi}{3}$$
$$\Leftrightarrow 4x=\pm\frac{\pi}{3}+2k\pi, k\in\mathbb{Z}$$
$$\Rightarrow x=\pm\frac{\pi}{12}+\frac{k\pi}{2}, k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\pm\frac{\pi}{12}+\frac{k\pi}{2}, k\in\mathbb{Z}}$

**លំហាត់បង្ហាត់បន្ថែម**

ក. $\sin^4 x+\cos^4 x=\frac{7}{8}\cot\left(x+\frac{\pi}{3}\right)\cot\left(\frac{\pi}{6}-x\right)$

សមីការមានឫសកាលណា $\begin{cases}\sin\left(x+\frac{\pi}{3}\right)\neq 0\\ \sin\left(\frac{\pi}{6}-x\right)\neq 0\end{cases}$

$$\Rightarrow \begin{cases} x \neq -\dfrac{\pi}{3} + k\pi \\ x \neq \dfrac{\pi}{6} + k\pi \end{cases}, k \in \mathbb{Z}$$

ដោយ $\cot\left(\dfrac{\pi}{6} - x\right) = \tan\left[\dfrac{\pi}{2} - \left(\dfrac{\pi}{6} - x\right)\right] = \tan\left(\dfrac{\pi}{3} + x\right)$

នោះ $\cot\left(x + \dfrac{\pi}{3}\right)\cot\left(\dfrac{\pi}{6} - x\right) = \cot\left(\dfrac{\pi}{3} + x\right) \cdot \tan\left(\dfrac{\pi}{3} + x\right) = 1$

ហើយ $\sin^4 x + \cos^4 x = \left(\sin^2 x + \cos^2 x\right)^2 - 2\sin^2 x \cos^2 x$

$$= 1 - \frac{1}{2}\sin^2 2x$$

យើងបានសមីការទៅជា $1 - \dfrac{1}{2}\sin^2 2x = \dfrac{7}{8}$

$$\Leftrightarrow 4\sin^2 2x = 1$$

$$\Leftrightarrow \sin^2 2x = \frac{1}{4}$$

$$\Leftrightarrow \sin 2x = \pm\frac{1}{2}$$

$$\Leftrightarrow \begin{bmatrix} \sin 2x = \dfrac{1}{2} \\ \sin 2x = -\dfrac{1}{2} \end{bmatrix}$$

`

$$\Leftrightarrow \begin{cases} \begin{cases} 2x = \dfrac{\pi}{6} + 2k\pi \\ 2x = \dfrac{5\pi}{6} + 2k\pi \end{cases} \\ \begin{cases} 2x = -\dfrac{\pi}{6} + 2k\pi \\ 2x = \dfrac{7\pi}{6} + 2k\pi \end{cases} \end{cases}, k \in \mathbb{Z}$$

$$\Leftrightarrow \begin{cases} \mathbf{x = \dfrac{\pi}{12} + k\pi} \\ \mathbf{x = \dfrac{5\pi}{12} + k\pi} \\ \mathbf{x = -\dfrac{\pi}{12} + k\pi} \\ \mathbf{x = \dfrac{7\pi}{12} + k\pi} \end{cases} \mathbf{, k} \in \mathbb{Z}$$

ខ. $5\sin x - 2 = 3(1-\sin x)\tan^2 x$

សមីការមានឫសកាលណា $\cos x \neq 0 \Rightarrow x \neq \dfrac{\pi}{2} + k\pi \ , k \in \mathbb{Z}$

យើងបាន $5\sin x - 2 = 3(1-\sin x)\cdot\dfrac{\sin^2 x}{\cos^2 x}$

$$\Leftrightarrow 5\sin x - 2 = 3\frac{(1-\sin x)\sin^2 x}{(1-\sin x)(1+\sin x)}$$

$$\Leftrightarrow 5\sin x - 2 = \frac{3\sin^2 x}{1+\sin x}$$

$$\Leftrightarrow 5\sin x + 5\sin^2 x - 2 - 2\sin x = 3\sin^2 x$$

$$\Leftrightarrow 2\sin^2 x + 3\sin x - 2 = 0$$

$$\Leftrightarrow (2\sin x-1)(\sin x+2)=0$$

$$\Leftrightarrow \left[\begin{array}{l}\sin x=\dfrac{1}{2}\\ \sin x=-2<-1\ (\text{មិនយក})\end{array}\right.$$

$$\Leftrightarrow \left[\begin{array}{l}x=\dfrac{\pi}{6}+2k\pi\\ x=\dfrac{5\pi}{6}+2k\pi\end{array}\right. ,\ k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\dfrac{\pi}{6}+2k\pi\ ,\ x=\dfrac{5\pi}{6}+2k\pi\ ,\ k\in\mathbb{Z}}$

គ. $\cos^2 3x\cos 2x-\cos^2 x=0$

ដោយ $\cos^2 3x=\dfrac{1+\cos 6x}{2}$

យើងបាន $\dfrac{1+\cos 6x}{2}\cdot\cos 2x-\cos^2 x=0$

$$\Leftrightarrow \frac{(1+\cos 6x)\cos 2x}{2}-\frac{1+\cos 2x}{2}=0$$

$$\Leftrightarrow \cos 2x+\cos 6x\cos 2x-1-\cos 2x=0$$

$$\Leftrightarrow \cos 6x\cos 2x-1=0$$

$$\Leftrightarrow (4\cos^3 2x-3\cos 2x)\cdot\cos 2x-1=0$$

$$\Leftrightarrow 4\cos^4 2x-3\cos^2 2x-1=0$$

តាង $t=\cos^2 2x$ ដែល $0\le t\le 1$

យើងបាន $4t^2-3t-1=0$

ដោយ $a+b+c=4-3-1=0$

នោះ $t_1=1, t_2=\dfrac{c}{2}=-\dfrac{1}{4}<0$ (មិនយក)

តែ $t=\cos^2 2x$ យើងបាន $\cos^2 2x=1$

$$\Leftrightarrow \cos 2x=\pm 1$$

$$\Leftrightarrow 2x=k\pi \ , k\in\mathbb{Z}$$

$$\Rightarrow x=\frac{k\pi}{2}, k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{k\pi}{2}, k\in\mathbb{Z}}$

ឃ. $\cos^4 x+\sin^4 x+\cos\left(x-\frac{\pi}{4}\right)\sin\left(3x-\frac{\pi}{4}\right)-\frac{3}{2}=0$

$(\cos^2x+\sin^2x)^2-2\cos^2x\sin^2x+\frac{1}{2}\left[\sin\left(x-\frac{\pi}{4}+3x-\frac{\pi}{4}\right)-\sin\left(x-\frac{\pi}{4}-3x+\frac{\pi}{4}\right)\right]-\frac{3}{2}=0$

$$\Leftrightarrow 1-\frac{1}{2}\sin^2 2x+\frac{1}{2}\sin\left(4x-\frac{\pi}{2}\right)+\frac{1}{2}\sin 2x-\frac{3}{2}=0$$

$$\Leftrightarrow -1-\sin^2 2x-\cos 4x+\sin 2x=0$$

$$\Leftrightarrow -1-\sin^2 2x-(1-2\sin^2 2x)+\sin 2x=0$$

$$\Leftrightarrow \sin^2 2x+\sin 2x-2=0$$

ដោយ $a+b+c=1+1-2=0$

នោះ $\left[\begin{array}{l}\sin 2x=1\\ \sin 2x=\frac{c}{a}=-2<-1 \text{ (មិនយក)}\end{array}\right.$

យើងបាន $\sin 2x=1\Leftrightarrow 2x=\frac{\pi}{2}+2k\pi, k\in\mathbb{Z}$

$$\Rightarrow x=\frac{\pi}{4}+k\pi \ , k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{\pi}{4}+k\pi \ , k\in\mathbb{Z}}$

ង. $\dfrac{2(\sin^6 x+\cos^6 x)-\sin x\cos x}{\sqrt{2}-2\sin x}=0$

សមីការមានឫសកាលណា $\sqrt{2}-2\sin x\neq 0$

$$\Leftrightarrow \sin x\neq \frac{\sqrt{2}}{2}$$

$$\Rightarrow \begin{cases} x\neq \dfrac{\pi}{4}+2k\pi \\ x\neq \dfrac{3\pi}{4}+2k\pi \end{cases}, k\in\mathbb{Z}$$

យើងបានសមីការទៅជា $2(\sin^6 x+\cos^6 x)-\sin x\cos x=0$

ដោយ $\sin^6x+\cos^6x=(\sin^2x+\cos^2x)^3-3\sin^2x\cos^2x(\sin^2x+\cos^2x)$

$$=1-\frac{3}{4}\sin^2 2x$$

យើងបាន $2\left(1-\dfrac{3}{4}\sin^2 2x\right)-\sin x\cos x=0$

$\Leftrightarrow 2-\dfrac{3}{2}\sin^2 2x-\dfrac{1}{2}\sin 2x=0$

$\Leftrightarrow 3\sin^2 2x+\sin 2x-4=0$

ដោយ $a+b+c=3+1-4=0$

នោះ $\left[\begin{array}{l} \sin 2x=1 \\ \sin 2x=\dfrac{c}{a}=-\dfrac{4}{3}<-1 \text{ (មិនយក)} \end{array}\right.$

យកបាន $\sin 2x=1\Leftrightarrow 2x=\dfrac{\pi}{2}+2k\pi\ ,k\in\mathbb{Z}$

$$\Rightarrow x=\frac{\pi}{4}+k\pi\ ,k\in\mathbb{Z}$$

តែ $\begin{cases} x \neq \dfrac{\pi}{4} + 2k\pi \\ x \neq \dfrac{3\pi}{4} + 2k\pi \end{cases}, k \in \mathbb{Z}$

នោះ $x \in \left\{ \left\{ \frac{\pi}{4} + k\pi \right\} - \left\{ \frac{\pi}{4} + 2k\pi \right\} \right\} = \left\{ \frac{\pi}{4} + (2k-1)\pi \right\}, k \in \mathbb{Z}$

ដូចនេះ សមីការមានចម្លើយ $\boxed{x = \frac{\pi}{4} + (2k-1)\pi, k \in \mathbb{Z}}$

លំហាត់ទី១៤ : ដោះស្រាយសមីការខាងក្រោម

ក. $\cos 7x - \sqrt{3}\sin 7x = -\sqrt{2}$

ខ. $\sin 3x = \sqrt{2} + \cos 3x$

គ. $3\sin x + \cos x = 1$

ឃ. $\sin x + 5\cos x = 1$

ង. $\frac{1+\sqrt{3}}{2\sqrt{2}}\sin x + \frac{1-\sqrt{3}}{2\sqrt{2}}\cos x = \frac{1}{\sqrt{2}}$

## ចំណោះស្រាយ

ក. $\cos 7x - \sqrt{3}\sin 7x = -\sqrt{2}$

ដោយ $r = \sqrt{1^2 + \sqrt{3}^2} = 2$

នោះចែកអង្គទាំងពីរនឹង 2

យើងបាន $\frac{1}{2}\cos 7x - \frac{\sqrt{3}}{2}\sin 7x = -\frac{\sqrt{2}}{2}$

$$\Leftrightarrow \cos\frac{\pi}{3}\cos 7x - \sin\frac{\pi}{3}\sin x = \cos\frac{3\pi}{4}$$

$$\Leftrightarrow \cos\left(7x+\frac{\pi}{3}\right) = \cos\frac{3\pi}{4}$$

$$\Leftrightarrow \left[\begin{array}{l} 7x+\dfrac{\pi}{3} = \dfrac{3\pi}{4} + 2k\pi \\ 7x+\dfrac{\pi}{3} = -\dfrac{3\pi}{4} + 2k\pi \end{array}\right. , k \in \mathbb{Z}$$

$$\Rightarrow \left[\begin{array}{l} x = \dfrac{5\pi}{84} + \dfrac{2k\pi}{7} \\ x = -\dfrac{13\pi}{84} + \dfrac{2k\pi}{7} \end{array}\right. , k \in \mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ

$$\boxed{x = \frac{5\pi}{84} + \frac{2k\pi}{7} \ , \ x = -\frac{13\pi}{84} + \frac{2k\pi}{7}, \quad k \in \mathbb{Z}}$$

ខ. $\sin 3x = \sqrt{2} + \cos 3x$

$$\Leftrightarrow \sin 3x - \cos 3x = \sqrt{2}$$

$$\Leftrightarrow \frac{\sqrt{2}}{2}\sin 3x - \frac{\sqrt{2}}{2}\cos 3x = 1$$

$$\Leftrightarrow \sin\left(3x-\frac{\pi}{4}\right) = 1$$

$$\Leftrightarrow 3x - \frac{\pi}{4} = \frac{\pi}{2} + 2k\pi \ , k \in \mathbb{Z}$$

$$\Rightarrow x = \frac{\pi}{4} + \frac{2k\pi}{3} \ , k \in \mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x = \dfrac{\pi}{4} + \dfrac{2k\pi}{3} \ , k \in \mathbb{Z}}$

គ. $3\sin x+\cos x=1$

**វិធីទី១**

ដោយ $r=\sqrt{3^2+1^2}=\sqrt{10}$

នោះចែកអង្គទាំងពីរនៃសមីការនឹង $\sqrt{10}$

គេបាន $\frac{3}{\sqrt{10}}\sin x+\frac{1}{\sqrt{10}}\cos x=\frac{1}{\sqrt{10}}$

តាង $\cos\alpha=\frac{1}{\sqrt{10}}$ និង $\sin\alpha=\frac{3}{\sqrt{10}}$

ដែល $\tan\alpha=\frac{\sin\alpha}{\cos\alpha}=3\Rightarrow\alpha=\arctan 3$

យើងបាន $\cos\alpha\cos x+\sin\alpha\sin x=\cos\alpha$

$$\Leftrightarrow \cos(x-\alpha)=\cos\alpha$$

$$\Leftrightarrow \begin{bmatrix} x-\alpha=\alpha+2k\pi \\ x-\alpha=-\alpha+2k\pi \end{bmatrix},\ k\in\mathbb{Z}$$

$$\Rightarrow \begin{bmatrix} x=2\alpha+2k\pi \\ x=2k\pi \end{bmatrix},\ k\in\mathbb{Z}$$

ដែល $\alpha=\arctan 3$

ដូចនេះ សមីការមានចម្លើយ

$$\boxed{x=2\arctan 3+2k\pi\ ,\ x=2k\pi\ ,k\in\mathbb{Z}}$$

**វិធីទី២**

☞ បើ $x=\pi+2k\pi$ នោះសមីការ $3\sin x+\cos x=1$

គឺ $3\sin(\pi+2k\pi)+\cos(\pi+2k\pi)=1$

$3\cdot 0-1=1$

$-1=1$ (មិនផ្ទៀងផ្ទាត់)

នោះ $x=\pi+2k\pi$ មិនមែនជាឫសនៃសមីការ $3\sin x+\cos x=1$ ទេ

☞ បើ $x\neq\pi+2k\pi$ តាង $t=\tan\frac{x}{2}$

នោះ $\cos x=\frac{1-t^2}{1+t^2}$ និង $\sin x=\frac{2t}{1+t^2}$

យើងបាន សមីការទៅជា $3\frac{2t}{1+t^2}+\frac{1-t^2}{1+t^2}=1$

$$\Leftrightarrow 6t+1-t^2=1+t^2$$
$$\Leftrightarrow 2t^2-6t=0$$
$$\Leftrightarrow 2t(t-3)=0$$
$$\Rightarrow t=0\ ,t=3$$

- $t=0\Leftrightarrow\tan\frac{x}{2}=0$

$$\Leftrightarrow\frac{x}{2}=k\pi$$
$$\Rightarrow x=2k\pi\ ,k\in\mathbb{Z}$$

- $t=3\Leftrightarrow\tan\frac{x}{2}=3$

$$\Leftrightarrow\frac{x}{2}=\arctan 3+k\pi$$
$$\Rightarrow x=2\arctan 3+2k\pi$$

ដូចនេះ សមីការមានចម្លើយ

$$\boxed{x=2\arctan 3+2k\pi\ ,\ x=2k\pi\ ,k\in\mathbb{Z}}$$

ឃ. $\sin x+5\cos x=1$

**វិធីទី១**

តាង $\tan\alpha=5\Rightarrow\alpha=\arctan 5$

យើងបានសមីការ $\sin x+\tan\alpha\cos x=1$

$$\Leftrightarrow \sin x\cos\alpha+\sin\alpha\cos x=\cos\alpha$$

$$\Leftrightarrow \sin(x+\alpha)=\sin\left(\frac{\pi}{2}-\alpha\right)$$

$$\Leftrightarrow \left[\begin{array}{l} x+\alpha=\dfrac{\pi}{2}-\alpha+2k\pi \\ x+\alpha=\pi-\dfrac{\pi}{2}+\alpha+2k\pi \end{array}\right. , k\in\mathbb{Z}$$

$$\Rightarrow \left[\begin{array}{l} x=\dfrac{\pi}{2}-2\alpha+2k\pi=\dfrac{\pi}{2}-2\arctan 5+2k\pi \\ x=\dfrac{\pi}{2}+2k\pi \end{array}\right. , k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ

$$\boxed{x=\frac{\pi}{2}+2k\pi\ ,\ x=\frac{\pi}{2}-2\arctan 5+2k\pi\ ,\ k\in\mathbb{Z}}$$

**វិធីទី២**

☞ បើ $x=\pi+2k\pi$ យើងបាន

$$\sin(\pi+2\mathrm{k}\,\pi)+5\cos(\pi+2\mathrm{k}\,\pi)=1$$

$$0-5=1 \quad \text{(មិនផ្ទៀងផ្ទាត់)}$$

នោះ $x=\pi+2k\pi$ មិនមែនជាឫសនៃសមីការ $\sin x+5\cos x=1$ ទេ

☞ បើ $x\neq\pi+2k\pi$ តាង $t=\tan\dfrac{x}{2}$

នោះ $\cos x=\frac{1-t^2}{1+t^2}$ , $\sin x=\frac{2t}{1+t^2}$

យើងបានសមីការទៅជា $\frac{2t}{1+t^2}+5\frac{1-t^2}{1+t^2}=1$

$$\Leftrightarrow 2t+5-5t^2=1+t^2$$
$$\Leftrightarrow 3t-t-2=0$$
$$\Rightarrow t=1, t=-\frac{2}{3}$$

- $t=1\Leftrightarrow \tan\frac{x}{2}=1$

$$\Leftrightarrow \frac{x}{2}=\frac{\pi}{4}+k\pi \ , k\in\mathbb{Z}$$
$$\Rightarrow x=\frac{\pi}{2}+2k\pi \ , k\in\mathbb{Z}$$

- $t=-\frac{2}{3}\Leftrightarrow \tan\frac{x}{2}=-\frac{2}{3}$

$$\Leftrightarrow \frac{x}{2}=\arctan\left(-\frac{2}{3}\right)+k\pi \ , k\in\mathbb{Z}$$
$$\Rightarrow x=2\arctan\left(-\frac{2}{3}\right)+2k\pi \ , k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ

$$\boxed{x=\frac{\pi}{2}+2k\pi \ , x=x=2\arctan\left(-\frac{2}{3}\right)+2k\pi \ , k\in\mathbb{Z}}$$

ង. $\frac{1+\sqrt{3}}{2\sqrt{2}}\sin x+\frac{1-\sqrt{3}}{2\sqrt{2}}\cos x=\frac{1}{\sqrt{2}}$

$$\Leftrightarrow \frac{\sqrt{2}+\sqrt{6}}{4}\sin x+\frac{\sqrt{2}-\sqrt{6}}{4}\cos x=\frac{\sqrt{2}}{2}$$

ដោយ $\cos\frac{7\pi}{12}=\cos\left(\frac{\pi}{3}+\frac{\pi}{4}\right)$

$$=\cos\frac{\pi}{3}\cos\frac{\pi}{4}-\sin\frac{\pi}{3}\sin\frac{\pi}{4}$$

$$=\frac{\sqrt{2}-\sqrt{6}}{4}$$

ហើយ $\sin\frac{7\pi}{12}=\cos\left(\frac{\pi}{3}+\frac{\pi}{4}\right)$

$$=\sin\frac{\pi}{3}\cos\frac{\pi}{4}+\cos\frac{\pi}{3}\sin\frac{\pi}{4}$$

$$=\frac{\sqrt{2}+\sqrt{6}}{4}$$

យើងបានសមីការទៅជា $\sin\frac{7\pi}{12}\sin x+\cos\frac{7\pi}{12}\cos x=\cos\frac{\pi}{4}$

$$\Leftrightarrow\cos\left(x-\frac{7\pi}{12}\right)=\cos\frac{\pi}{4}$$

$$\Leftrightarrow\begin{cases}x-\frac{7\pi}{12}=\frac{\pi}{4}+2k\pi\\ x-\frac{7\pi}{12}=-\frac{\pi}{4}+2k\pi\end{cases},k\in\mathbb{Z}$$

$$\Rightarrow\begin{cases}x=\frac{5\pi}{6}+2k\pi\\ x=\frac{\pi}{3}+2k\pi\end{cases},k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{5\pi}{6}+2k\pi\,,\,x=\frac{\pi}{3}+2k\pi\,,\,k\in\mathbb{Z}}$

លំហាត់ទី១៥ : ដោះស្រាយសមីការខាងក្រោម ៖

ក. $8\sin x=\dfrac{\sqrt{3}}{\cos x}+\dfrac{1}{\sin x}$

ខ. $\left(\sin 2x+\sqrt{3}\cos 2x\right)^2-5=\cos\left(2x-\dfrac{\pi}{6}\right)$

គ. $2\sqrt{2}\left(\sin x+\cos x\right)\cos x=3+\cos 2x$

## ចំណោះស្រាយ

ក. $8\sin x=\dfrac{\sqrt{3}}{\cos x}+\dfrac{1}{\sin x}$

សមីការមានឫសកាលណា $\begin{cases}\cos x\neq 0\\ \sin x\neq 0\end{cases}$

$$\Leftrightarrow \sin 2x\neq 0$$

$$\Rightarrow x\neq\frac{k\pi}{2}\ ,k\in\mathbb{Z}$$

យើងបាន $8\sin x=\dfrac{\sqrt{3}}{\cos x}+\dfrac{1}{\sin x}$

$$\Leftrightarrow 8\sin^2 x\cos x=\sqrt{3}\sin x+\cos x$$

$$\Leftrightarrow 8\frac{1-\cos 2x}{2}\cos x=\sqrt{3}\sin x+\cos x$$

$$\Leftrightarrow 4\cos x-4\cos x\cos 2x=\sqrt{3}\sin x+\cos x$$

$$\Leftrightarrow -4\cdot\frac{1}{2}\left(\cos 3x+\cos x\right)=\sqrt{3}\sin x-3\cos x$$

$$\Leftrightarrow -2\cos 3x=\sqrt{3}\sin x-\cos x$$

$$\Leftrightarrow \cos 3x = \frac{1}{2}\cos x - \frac{\sqrt{3}}{2}\sin x$$

$$\Leftrightarrow \cos 3x = \cos\left(x + \frac{\pi}{3}\right)$$

$$\Leftrightarrow \begin{cases} 3x = x + \frac{\pi}{3} + 2k\pi \\ 3x = -\left(x + \frac{\pi}{3}\right) + 2k\pi \end{cases}, k \in \mathbb{Z}$$

$$\Rightarrow \begin{cases} x = \frac{\pi}{6} + k\pi \\ x = -\frac{\pi}{12} + \frac{k\pi}{2} \end{cases}, k \in \mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x = \frac{\pi}{6} + k\pi \text{ , } x = -\frac{\pi}{12} + \frac{k\pi}{2}, k \in \mathbb{Z}}$

ខ. $\left(\sin 2x + \sqrt{3}\cos 2x\right)^2 - 5 = \cos\left(2x - \frac{\pi}{6}\right)$

$$\Leftrightarrow 4\left(\frac{\sqrt{3}}{2}\cos 2x + \frac{1}{2}\sin 2x\right)^2 - 5 = \cos\left(2x - \frac{\pi}{6}\right)$$

$$\Leftrightarrow 4\cos^2\left(2x - \frac{\pi}{6}\right) - \cos\left(2x - \frac{\pi}{6}\right) - 5 = 0$$

តាង $\cos\left(2x - \frac{\pi}{6}\right) = t$ ដែល $-1 \le t \le 1$

យើងបាន $4t^2 - t - 5 = 0$

$$\Rightarrow \begin{cases} t = -1 \\ t = \frac{c}{a} = \frac{5}{4} > 1 \text{ (មិនយក)} \end{cases}$$

យើងបាន $\cos\left(2x-\frac{\pi}{6}\right)=-1$

$$\Leftrightarrow 2x-\frac{\pi}{6}=\pi+2k\pi \ , k\in\mathbb{Z}$$

$$\Rightarrow x=\frac{7\pi}{12}+k\pi \ , k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{7\pi}{12}+k\pi \ , k\in\mathbb{Z}}$

គ. $2\sqrt{2}\left(\sin x+\cos x\right)\cos x=3+\cos 2x$

$$\Leftrightarrow 2\sqrt{2}\sin x\cos x+2\sqrt{2}\cos^2 x=3+\cos 2x$$

$$\Leftrightarrow \sqrt{2}\sin 2x+2\sqrt{2}\frac{1+\cos 2x}{2}=3+\cos 2x$$

$$\Leftrightarrow \sqrt{2}\sin 2x+(\sqrt{2}-1)\cos 2x=3-\sqrt{2}$$

ដោយ $\sqrt{2}^2+(\sqrt{2}-1)^2=2+2-2\sqrt{2}+1=5-2\sqrt{2}$

ហើយ $(3-\sqrt{2})^2=9-6\sqrt{2}+2=11-6\sqrt{2}$

នោះ $(\sqrt{2})^2+(\sqrt{2}-1)^2<(3-\sqrt{2})^2$

ដូចនេះ សមីការគ្មានឫស

លំហាត់ទី១៦ : ដោះស្រាយសមីការខាងក្រោម ៖

ក. $\sin^3 x-\sqrt{3}\cos^3 x=\sin x\cos^2 x-\sqrt{3}\sin^2 x\cos x$

ខ. $\frac{(1-2\sin x)\cos x}{(1+2\sin x)(1-\sin x)}=\sqrt{3}$

គ. $\sin x+\cos x\sin 2x+\sqrt{3}\cos 3x=2(\cos 4x+\sin^3 x)$

## ចំណោះស្រាយ

ក. $\sin^3 x-\sqrt{3}\cos^3 x=\sin x\cos^2 x-\sqrt{3}\sin^2 x\cos x$

$\Leftrightarrow \sin^2 x(\sin x+\sqrt{3}\cos x)-\cos^2 x(\sin x+\sqrt{3}\cos x)=0$

$\Leftrightarrow (\sin x+\sqrt{3}\cos x)(\sin^2 x-\cos^2 x)=0$

$\Leftrightarrow -2\cos 2x\left(\frac{1}{2}\sin x+\frac{\sqrt{3}}{2}\cos x\right)=0$

$\Leftrightarrow \cos 2x\cos\left(x-\frac{\pi}{6}\right)=0$

$\Leftrightarrow \left[\begin{array}{l}\cos 2x=0\\ \cos\left(x-\frac{\pi}{6}\right)=0\end{array}\right.$

$\Leftrightarrow \left[\begin{array}{l}2x=\frac{\pi}{2}+k\pi\\ x-\frac{\pi}{6}=\frac{\pi}{2}+k\pi\end{array}\right.,k\in\mathbb{Z}$

$\Rightarrow \left[\begin{array}{l}x=\frac{\pi}{4}+\frac{k\pi}{2}\\ x=\frac{2\pi}{3}+k\pi\end{array}\right.,k\in\mathbb{Z}$

ដូចនេះ សមីការមានចម្លើយ $\boxed{x=\frac{\pi}{4}+\frac{k\pi}{2},x=\frac{2\pi}{3}+k\pi,\mathrm{k}\in\mathbb{Z}}$

ខ. $\frac{(1-2\sin x)\cos x}{(1+2\sin x)(1-\sin x)}=\sqrt{3}$

សមីការមានឫសកាលណា $\begin{cases}1+2\sin x\neq 0\\ 1-\sin x\neq 0\end{cases}$

$$\Rightarrow \begin{cases} x \neq -\dfrac{\pi}{6} + 2k\pi \\ x \neq \dfrac{7\pi}{6} + 2k\pi \\ x \neq \dfrac{\pi}{2} + 2k\pi \end{cases}, k \in \mathbb{Z}$$

គេបាន សមីការ $(1-2\sin x)\cos x = \sqrt{3}(1+2\sin x)(1-\sin x)$

$\Leftrightarrow \cos x - 2\sin x\cos x = \sqrt{3}\left(1-\sin x+2\sin x-2\sin^2 x\right)$

$\Leftrightarrow \cos x - 2\sin x\cos x = \sqrt{3}-\sqrt{3}\sin x+2\sqrt{3}\sin x-\sqrt{3}+\sqrt{3}\cos 2x$

$\Leftrightarrow \cos x - \sqrt{3}\sin x = 2\sin x\cos x+\sqrt{3}\cos 2x$

$\Leftrightarrow \dfrac{1}{2}\cos x - \dfrac{\sqrt{3}}{2}\sin x = \dfrac{1}{2}\sin 2x+\dfrac{\sqrt{3}}{2}\cos 2x$

$\Leftrightarrow \cos\left(x+\dfrac{\pi}{3}\right) = \cos\left(2x-\dfrac{\pi}{6}\right)$ ឬ $\cos\left(2x-\dfrac{\pi}{6}\right) = \cos\left(x+\dfrac{\pi}{3}\right)$

$$\Leftrightarrow \begin{cases} 2x-\dfrac{\pi}{6} = x+\dfrac{\pi}{3}+2k\pi \\ 2x-\dfrac{\pi}{6} = -x-\dfrac{\pi}{3}+2k\pi \end{cases}, k \in \mathbb{Z}$$

$$\Rightarrow \begin{cases} x = \dfrac{\pi}{2}+2k\pi \\ x = -\dfrac{\pi}{18}+\dfrac{2k\pi}{3} \end{cases}, k \in \mathbb{Z}$$

តែ $x \neq \dfrac{\pi}{2}+2k\pi$

ដូចនេះ សមីការមានចម្លើយ $\boxed{x = -\dfrac{\pi}{18}+\dfrac{2k\pi}{3}, k \in \mathbb{Z}}$

គ. $\sin x+\cos x\sin 2x+\sqrt{3}\cos 3x=2(\cos 4x+\sin^3 x)$

$\Leftrightarrow \sin x+\frac{1}{2}\left(\sin 3x+\sin x\right)+\sqrt{3}\cos 3x=2\left(\cos 4x+\sin^3 x\right)$

$\Leftrightarrow 3\sin x+\sin 3x+2\sqrt{3}\cos 3x=4\cos 4x+4\sin^3 x$

$\Leftrightarrow 3\sin x+\sin 3x+2\sqrt{3}\cos 3x=4\cos 4x+4\left(\frac{3\sin x-\sin 3x}{4}\right)$

$\Leftrightarrow 3\sin x+\sin 3x+2\sqrt{3}\cos 3x=4\cos 4x+3\sin x-\sin 3x$

$\Leftrightarrow 2\sin 3x+2\sqrt{3}\cos 3x=4\cos 4x$

$\Leftrightarrow \frac{\sqrt{3}}{2}\cos 3x+\frac{1}{2}\sin 3x=\cos 4x$

$\Leftrightarrow \cos\left(3x-\frac{\pi}{6}\right)=\cos 4x$

$\Leftrightarrow \left[\begin{array}{l} 4x=3x-\frac{\pi}{6}+2k\pi \\ 4x=-3x+\frac{\pi}{6}+2k\pi \end{array}\right. , k\in\mathbb{Z}$

$\Rightarrow \left[\begin{array}{l} x=-\frac{\pi}{6}+2k\pi \\ x=\frac{\pi}{42}+\frac{2k\pi}{7} \end{array}\right. , k\in\mathbb{Z}$

ដូចនេះ សមីការមានចម្លើយ $\boxed{x=-\frac{\pi}{6}+2k\pi\ ,\ x=\frac{\pi}{42}+\frac{2k\pi}{7},\ k\in\mathbb{Z}}$

លំហាត់ទី១៧ : ដោះស្រាយសមីការខាងក្រោម៖

ក. $\cos x+\sin x-\sin x\cos x=1$

ខ. $(1+\sqrt{2})(\sin x+\cos x)-\sin 2x-1-\sqrt{2}=0$

គ. $5\sin 2x-12(\sin x-\cos x)+12=0$

ឃ. $\cos x\sin x=6(\sin x-\cos x-1)$

## ចំណោះស្រាយ

ក. $\cos x+\sin x-\sin x\cos x=1$

តាង $t=\cos x+\sin x=\sqrt{2}\sin\left(x+\frac{\pi}{4}\right)$ ដែល $t\in\left[-\sqrt{2},\sqrt{2}\right]$

នោះ $\sin x\cos x=\frac{t^2-1}{2}$

យើងបានសមីការទៅជា $t-\frac{t^2-1}{2}=1$

$$\Leftrightarrow 2t-t^2+1=2$$
$$\Leftrightarrow t^2-2t+1=0$$
$$\Leftrightarrow (t-1)^2=0$$
$$\Rightarrow t=1$$

យើងបាន $t=1=\sqrt{2}\sin\left(x+\frac{\pi}{4}\right)$

$$\Leftrightarrow \sin\left(x+\frac{\pi}{4}\right)=\frac{\sqrt{2}}{2}$$

$$\Leftrightarrow \left[\begin{array}{l} x+\dfrac{\pi}{4}=\dfrac{\pi}{4}+2k\pi \\ x+\dfrac{\pi}{4}=\dfrac{3\pi}{4}+2k\pi \end{array}\right. , k\in\mathbb{Z}$$

$$\Rightarrow \left[\begin{array}{l} x=2k\pi \\ x=\dfrac{\pi}{2}+2k\pi \end{array}\right. , k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ $\boxed{x=2k\pi\ ,\ x=\dfrac{\pi}{2}+2k\pi\ ,\ k\in\mathbb{Z}}$

ខ. $(1+\sqrt{2})(\sin x+\cos x)-\sin 2x-1-\sqrt{2}=0$

តាង $t=\sin x+\cos x=\sqrt{2}\sin\left(x+\dfrac{\pi}{4}\right)$ ដែល $t\in\left[-\sqrt{2}\ ,\sqrt{2}\right]$

នោះ $\sin 2x=2\sin x\cos x=2\dfrac{t^2-1}{2}=t^2-1$

យើងបាសមីការ $(1+\sqrt{2})t-(t^2-1)-1-\sqrt{2}=0$

$$\Leftrightarrow t^2-(1+\sqrt{2})t+\sqrt{2}=0$$

ដោយ $a+b+c=1-(1+\sqrt{2})+\sqrt{2}=0$

នោះ $t_1=1, t_2=\dfrac{c}{a}=\sqrt{2}$

យើងបាន ៖ • $t=1\Leftrightarrow\sqrt{2}\sin\left(x+\dfrac{\pi}{4}\right)=1$

$$\Rightarrow \left[\begin{array}{l} x=2k\pi \\ x=\dfrac{\pi}{2}+2k\pi \end{array}\right. , k\in\mathbb{Z}$$ (តាមសម្រាយ(ក))

- $t=\sqrt{2} \Leftrightarrow \sqrt{2}\sin\left(x+\frac{\pi}{4}\right)=\sqrt{2}$

$$\Leftrightarrow \sin x\left(x+\frac{\pi}{4}\right)=1$$

$$\Leftrightarrow x+\frac{\pi}{4}=\frac{\pi}{2}+2k\pi$$

$$\Rightarrow x=\frac{\pi}{4}+2k\pi\,,\ k\in\mathbb{Z}$$

ដូចនេះ សមីការមានចម្លើយ

$$\boxed{x=2k\pi\,,\ x=\frac{\pi}{2}+2k\pi\,,\ x=\frac{\pi}{4}+2k\pi\,,\ k\in\mathbb{Z}}$$

គ. $5\sin 2x-12\left(\sin x-\cos x\right)+12=0$

តាង $\mathrm{t}=\sin x-\cos x=\sqrt{2}\sin\left(x-\frac{\pi}{4}\right)$ ដែល $t\in\left[-\sqrt{2}\,,\sqrt{2}\right]$

